00641508

E9/1/1

# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 03 / 02 / 2011
ម៉ោង (Time/Heure): 14:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

## អង្គជំនុំជម្រះសាលាដំបូង

អនុស្សរណៈអន្តរការិយាល័យ

**ជូនចំពោះ:** **គ្រប់ភាគីទាំងអស់ សំណុំរឿង ០០២** កាលបរិច្ឆេទ: ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១១

**ចម្លងជូន:** ប្រធាន និងចៅក្រមទាំងអស់នៃអង្គជំនុំជម្រះសាលាដំបូង

**ពី:** Susan LAMB មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ:** **យោងព័ត៌មានសាក្សី វិធានការការពារ និងប្រភេទនៃសម្បថ (ឧបសម្ព័ន្ធ២ក និង២ខ ដីកាបង្គាប់ឲ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ** (E9.2))

នាងខ្ញុំសូមយោងទៅដល់ "សំណើរបស់មេធាវីការពារក្ដី អ្នកស្រី អៀង ធីរិទ្ធ ពាក់ព័ន្ធនឹងដីកាបង្គាប់ឲ្យភាគីដាក់សម្ភារៈ ដើម្បីរៀបចំសវនាការ" (ឯកសារលេខ E9/1)។ នៅក្នុងសំណើនេះ មេធាវីការពារក្ដី អ្នកស្រី អៀង ធីរិទ្ធ កត់សម្គាល់ពីលទ្ធភាពដែលខ្លួនមិនអាចផ្តល់អាសយដ្ឋានបច្ចុប្បន្ន និងព័ត៌មានលម្អិតសម្រាប់ទំនាក់ទំនងរបស់សាក្សីដែលខ្លួនបានស្នើសុំ ទៅតាមដីការបស់អង្គជំនុំជម្រះសាលាដំបូងបង្គាប់ឲ្យដាក់សម្ភារៈ (ឯកសារលេខ E9) ដែលជាព័ត៌មានពាក់ព័ន្ធនឹងវិធានការការពារ និងប្រភេទនៃសម្បថដែលនៅជាធរមានបានទេ។ ម្យ៉ាង ដោយសារព័ត៌មានភាគច្រើនដែលពាក់ព័ន្ធនឹងសាក្សី ដែលត្រូវបានសាកសួរយកចម្លើយ ដោយសហចៅក្រមស៊ើបអង្កេត (ក.ស.ច.ស) មាននៅក្នុងសំណុំរឿង ដែលមានតែ ក.ស.ច.ស ទេទើបអាចប្រើប្រាស់បាន ប៉ុន្តែភាគីដទៃទៀតមិនអាចប្រើប្រាស់បានទេ។

អង្គជំនុំជម្រះសាលាដំបូងបានទទួលព័ត៌មានស្រដៀងគ្នានេះដែរ ពីភាគីដទៃទៀត ហើយខ្លួនក៏បានបញ្ជាក់ពីឧបសគ្គទាំងនេះ។ ដោយសហការណ៍ការងារជាមួយអង្គភាពគាំពារសាក្សី និងអ្នកជំនាញ (WESU) អង្គជំនុំជម្រះសាលាដំបូងមុខជានឹងបានទទួលព័ត៌មានទាក់ទិននឹងសាក្សី ដែលបានសាកសួរយកចម្លើយដោយ ក.ស.ច.ស រួចហើយ។

អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូងសូមបញ្ជាក់ថា ឧបសម្ព័ន្ធ២ នៃដីការបស់អង្គជំនុំជម្រះសាលាដំបូងបង្គាប់ឲ្យដាក់សម្ភារៈតម្រូវឲ្យភាគីដាក់ព័ត៌មានដែលពាក់ព័ន្ធទាំងអស់ ដែលភាគីអាចស្វែងរកបាន។ ប្រការនេះនឹងពាក់ព័ន្ធជាសំខាន់ទៅដល់សាក្សីនានា ដែលភាគីខ្លួនឯងបានស្នើមកអង្គជំនុំជម្រះសាលាដំបូងជាលើកដំបូង។

E9/1/1

អនុស្សរណៈនេះជាការឆ្លើយតបជាផ្លូវការរបស់អង្គជំនុំជម្រះសាលាដំបូងចំពោះសំណើលេខ E9/1។ ដោយសារព័ត៌មាននៅក្នុងអនុស្សរណៈនេះមានការពាក់ព័ន្ធជាទូទៅដល់គ្រប់ភាគី ហេតុនេះទើបអនុស្សរណៈនេះត្រូវបានចែកជូនទៅគ្រប់ភាគីទាំងអស់។

សូមទទួលនូវការគោរពរាប់អានដ៏ខ្ពង់ខ្ពស់ពីនាងខ្ញុំ។